# ប្រការគួរយល់ដឹងដើម្បីកាត់បន្ថយ គ្រោះភ័យនៃគ្រោះទឹកជំនន់

## មុនពេលទឹកជំនន់



ត្រូវធ្វើធ្នើរសំរាប់ដាក់របស់របរ និងអុសដុតនៅពេលទឹកជំនន់




ត្រូវត្រៀមសម្ភារៈសង្គ្រោះបន្ទាន់ ម្ហូបអាហារ និងសម្ភារៈប្រើប្រាស់ទុកជាមុន



ត្រូវរៀបចំឯកសារសំខាន់ៗ ច្រកចូលក្នុងថង់មិនជ្រាបទឹក និងដាក់ផុតពីកន្លែងសើម



ត្រូវជួសជុលទូក និងមធ្យោបាយធ្វើដំណើរសំរាប់ប្រើប្រាស់ពេលទឹកជំនន់



ត្រូវធ្វើធ្នើរសំរាប់ដាំបន្លែហូប និងដាក់សត្វពាហនៈនៅរដូវទឹកជំនន់



ត្រូវស្តាប់ និងតាមដានព័ត៌មានព្យាករណ៍កំពស់ទឹក តាមវិទ្យុ និងទូរទស្សន៍ជាប្រចាំមុន និងក្នុងពេលទឹកជំនន់

ផលិតដោយ MRC adpc
ដៃគូជាមួយ CNMC World Vision
ឧបត្ថម្ភដោយ gtz Partner for the Future Worldwide on behalf of: Federal Ministry for Economic Cooperation and Development; EUROPEAN COMMISSION Humanitarian Aid

# ប្រការគួរយល់ដឹងដើម្បីកាត់បន្ថយ
# គ្រោះភ័យនៃគ្រោះទឹកជំនន់

## អំឡុងពេលទឹកជំនន់



នៅពេលស្នាក់នៅលើទីទួលសុវត្ថិភាព ត្រូវស្តាប់ ឬតាមដានព័ត៌មានព្យាករណ៍ទឹកជំនន់ជាប្រចាំ



ត្រូវទទួលទានទឹកស្អាត គ្មានមេរោគ ដោយប្រើថ្នាំក្លរ៉ូមីន រឺអាល់បែត ទឹកចំរោះ និងទឹកឆ្អិន




ត្រូវជម្លៀសទៅរកតំបន់ដែលមានសុវត្ថិភាពនៅពេលមានទឹកជំនន់ ឬ នៅពេលទទួលបានព័ត៌មានប្រកាសភាពអាសន្ន



ត្រូវពាក់ស្បែកជើងកវែង និងយកឈើលើកខ្សែភ្លើងដែលធ្លាក់ចូលទឹក ដោយកុំយកដៃប៉ះពាល់ដាច់ខាត



កុំបណ្តោយអោយក្មេងហែល និងលោតទឹកលេង នៅពេលទឹកជំនន់



ត្រូវត្រងទឹកភ្លៀងទុកសំរាប់ប្រើប្រាស់ និងទទួលទាន នៅពេលទឹកជំនន់

ផលិតដោយ

MRC · adpc

ដៃគូជាមួយ

CNMC · World Vision

ឧបត្ថម្ភដោយ

gtz Partner for the Future Worldwide on behalf of: Federal Ministry for Economic Cooperation and Development · EUROPEAN COMMISSION Humanitarian Aid

# ប្រការគួរយល់ដឹងដើម្បីកាត់បន្ថយ
# គ្រោះភ័យនៃគ្រោះទឹកជំនន់

## ក្រោយពេលទឹកជំនន់



ត្រូវកត់ត្រាទុកនូវអ្វីដែលបានខូចខាតពីគ្រោះទឹកជំនន់ដើម្បី កត់សំគាល់ និងត្រៀមបង្ការនៅពេលទឹកជំនន់ឆ្នាំក្រោយ



ត្រូវជីកកប់កាកសំណល់រឹងនិងរាវព្រមទាំងសត្វស្លាប់ ដោយសារទឹកជំនន់



ត្រូវបោសសំអាត និងសំងួតខាងក្នុងផ្ទះ មុនពេលត្រឡប់ ទៅស្នាក់នៅវិញ



ត្រូវចូលរួមផ្តល់យោបល់សំរាប់ត្រៀមបង្ការ និងកាត់បន្ថយ គ្រោះថ្នាក់គ្រោះទឹកជំនន់នៅតាមសហគមន៍



ត្រូវបោសសំអាតខាងក្រៅផ្ទះសម្បែង និងបរិវេនលំនៅដ្ឋាន អោយបានល្អ មុនពេលត្រឡប់ទៅស្នាក់នៅវិញ



មិនត្រូវឡើងលេងលើដំបូលផ្ទះ និងគំនរបាក់បែកដោយ ទឹកជំនន់


ផលិតដោយ

MRC adpc

ដៃគូជាមួយ

CNMC World Vision

ឧបត្ថម្ភដោយ

gtz Partner for the Future Worldwide on behalf of:

Federal Ministry for Economic Cooperation and Development

EUROPEAN COMMISSION Humanitarian Aid

# ការត្រៀមបង្ការ និងកាត់បន្ថយផលប៉ះពាល់លើកុមារ
# ពីគ្រោះភ័យនៃគ្រោះទឹកជំនន់

## សកម្មភាពដែលមនុស្សពេញវ័យ និងកុមារ គួរធ្វើ និង មិនគួរធ្វើនៅពេលទឹកជំនន់

### គួរធ្វើ



ណែនាំកូនចៅ ឱ្យចេះប្រើប្រាស់សម្ភារៈការពារនៅពេលទឹកជំនន់

### គួរធ្វើ



ពេលជូន ឬពេលក្មេងធ្វើដំណើរទៅ និងមកពីសាលារៀន ត្រូវប្រើប៊ីដុងទឹក ពោះវៀនកង់ឡាន អាវពោងដើម្បី ការពារនៅពេលទឹកជំនន់

### គួរធ្វើ



ត្រូវធ្វើរនាំងដើម្បីការពារក្មេងៗកុំអោយធ្លាក់ទឹក

### គួរធ្វើ



អាណាព្យាបាលត្រូវជូនកូនៗទៅ និងទទួលមកពីសាលារៀនវិញនៅរដូវទឹកជំនន់

### មិនគួរធ្វើ



ពេលរដូវទឹកជំនន់ ត្រូវហាមឃាត់ក្មេងៗកុំអោយទៅបេះបន្លែ ដើម្បីលក់ដោយគ្មានមនុស្សចាស់ទៅជាមួយ

### មិនគួរធ្វើ



ត្រូវហាមកុំអោយក្មេងៗប្រកបរបរគ្រោះថ្នាក់ ដូចជាដាក់មង ឬស្ទូចត្រីនៅពេលទឹកជំនន់

ផលិតដោយ MRC adpc

ដៃគូជាមួយ CNMC World Vision

ឧបត្ថម្ភដោយ gtz Partner for the Future Worldwide on behalf of: Federal Ministry for Economic Cooperation and Development

EUROPEAN COMMISSION Humanitarian Aid

# ការត្រៀមបង្ការ និងកាត់បន្ថយផលប៉ះពាល់លើកុមារ
# ពីគ្រោះភ័យនៃគ្រោះទឹកជំនន់

## សកម្មភាពដែលក្មេង គួរធ្វើ នៅពេលមានទឹកជំនន់

### គួរធ្វើ



ត្រូវបង្រៀនក្មេងៗនៅតាមតំបន់លិចទឹកអោយចេះហែលទឹក

### គួរធ្វើ



ពេលធ្វើដំណើរតាមទូកឬកាណូតត្រូវយកសម្ភារៈការពារ
ទៅតាមដូចជា ប៊ីដុងទឹក ពោះវៀនកង់ឡាន អាវពោង

### គួរធ្វើ



ពេលដែលមានក្មេងលង់ទឹកត្រូវផ្តល់ពត៌មាន និងហៅមនុស្សធំឱ្យ
ជួយសង្គ្រោះអោយបានទាន់ពេល

## សកម្មភាពដែលក្មេង មិនគួរធ្វើ នៅពេលមានទឹកជំនន់

### មិនគួរធ្វើ



ពួកយើងមិនត្រូវលេងក្បែរមាត់ទឹក និងកន្លែងដែលមានច្រាំងបាក់

### មិនគួរធ្វើ



មិនត្រូវស្ទូចត្រីលេងនៅពេលមានទឹកជំនន់

### មិនគួរធ្វើ



មិនត្រូវចុះបេះបន្លែនៅក្នុងទឹកនៅពេលមានទឹកជំនន់


ផលិតដោយ
MRC adpc

ដៃគូជាមួយ
CNMC World Vision

ឧបត្ថម្ភដោយ
gtz Partner for the Future Worldwide
on behalf of:
Federal Ministry for Economic Cooperation and Development
EUROPEAN COMMISSION
Humanitarian Aid